ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដំណាំខ្នុរការ៉ុត





# ដំណាំខ្នុរការ៉ុត

## ១. ផ្ទៃដីដាំដុះ និងបរិមាណផលដំណាំខ្នុរគ្រប់ប្រភេទ ក្នុងឆ្នាំ២០២០

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្នុងឆ្នាំ២០២០ នៅទូទាំងប្រទេសដំណាំខ្នុរគ្រប់ប្រភេទដាំដុះបាន÷

| ល.រ | លក្ខណៈដាំដុះ | ផ្ទៃដីដាំដុះសរុប (ហិកតា) | ផ្ទៃដីទទួលផល សរុប(ហិកតា) | ទិន្នផលជាមធ្យម (តោន/ហិកតា) | បរិមាណផលសរុប (តោន) |
|---|---|---|---|---|---|
| ១ | លក្ខណៈគ្រួសារ | ៥ ៦៧៤ | ៤ ៤៩៦ | ១៨.៣៥ | ៨២ ៤៩០ |
| ២ | លក្ខណៈក្រុមហ៊ុន | ៧៧៦ | ៣០ | ២០ | ៦០០ |
| សរុប | | ៦ ៤៥០ | ៤ ៥២៦ | ១៨.៣៥ | ៨៣ ០៩០ |

## ២.ទិន្នផល

ពូជខ្នុរការ៉ុតដែលត្រូវតាមស្តង់ដារសម្រាប់នាំចេញគឺពូជខ្នុរការ៉ុតប្រភេទថ្មីរបស់វៀតណាមដែលដាំបានទិន្នផលខ្ពស់ ផ្លែមូលល្អ សាច់ច្រើន និងមានរសជាតិផ្អែម។ តាមការអនុវត្តជាក់ស្តែង ខ្នុរការ៉ុតប្រភេទពូជថ្មីរបស់វៀតណាមដែលកសិករក៏ដូចជាក្រុមហ៊ុននិយមដាំនាពេលបច្ចុប្បន្នគឺទទួលបានទិន្នផលចាប់ពី ២៦តោន ដល់៣០តោនក្នុង១ឆ្នាំ និងក្នុង១ផ្លែមានទម្ងន់ពី ១០គ.ក ទៅ ២០គ.ក។ ផ្លែខ្នុរដែលត្រូវតាមស្តង់ដារនាំចេញគឺមានទម្ងន់ចាប់ពី៩គ.ក ឡើងទៅ និងមានសណ្ឋានមូលល្អ។

## ៣.រយៈពេលដាំដុះរហូតទទួលផល

ខ្នុរការ៉ុតចាប់ផ្តើមចេញផ្កា ក្តីប នៅខែទី១២ ឬ ខែទី១៣ បន្ទាប់ពីការដាំដុះ និងប្រមូលផលវគ្គដំបូងគឺក្នុងកំឡុងខែទី១៨ ទៅខែទី១៩។

## ៤.អាយុកាលរបស់ខ្នុរ

ប្រសិនមានការថែទាំដឹតដល់ មិនមានឱ្លងស៊ី ខ្នុរអាចមានអាយុពី១៥ទៅ២០ ឆ្នាំ។

## ៥.ការប្រមូលផល

ការប្រមូលផលជាបន្ទុករបស់អ្នកទិញ ដែលចុះទៅប្រមូលទិញដល់ចម្ការ ដោយបេះតែផ្លែខ្នុរណាចាស់ត្រឹមត្រូវ និងមានទ្រង់ទ្រាយល្អ។

## ៦.ទីផ្សារ

ខ្នុរការ៉ុតគឺសម្រាប់លក់ក្នុងស្រុក និងនាំចេញទៅប្រទេសវៀតណាម និងប្រទេសចិនជាប្រភេទខ្នុរម្វូលស្រស់។










## ៧.និន្នាការតម្លៃ

- តម្លៃទាបបំផុត ១២០០រៀល/គ.ក និងតម្លៃខ្ពស់បំផុត ២៦០០រៀល/គ.ក តម្លៃខ្នុរម្វូល ឈ្មួញចុះទៅទិញដល់ចម្ការ។ តម្លៃបច្ចុប្បន្ន ២០០០រៀល-២៣០០រៀល/គ.ក។
- សម្រាប់ការលក់រាយក្នុងស្រុក តម្លៃខ្នុរម្វូលពី ៣០០០រៀល ទៅ៥០០០រៀល/គ.ក។

### ៨.បច្ចេកទេសនៃការដាំដុះ និងថែទាំ

**ក)-ការរៀបចំដី និងកាប់រណ្ដៅ÷**

-ភ្ជួរលើកទី១ ហាលចោលឱ្យឆ្អិនដី និងលើកទី២ ភ្ជួរប្រែ រាស់ និងភ្ជួរពូនរង (ដើម្បីកុំឱ្យជាំទឹក) រងកម្ពស់ ០.៤ម៉ ទទឹងរង ៣ម៉ ដាំកណ្ដាលរង។

-ជីករណ្ដៅជម្រៅ ០.៤ម៉ ទំហំ ០.៤ម៉x០.៤ម៉ (គឺអាស្រ័យទៅតាមប្រភេទដីសំបូរជីជាតិ ដីល្អផុស ដីធូរ ឬ ដី ខ្សាច់រឹង)។ គម្លាតពីរណ្ដៅមួយទៅរណ្ដៅមួយពី ៣ម៉ ទៅ ៣.៥០ម៉។ សម្រាប់ពូជខ្នុរការ៉ុតថ្មីរបស់វៀតណាមដាំ ពីគុម្ព១ទៅ១គម្លាត ៣ម៉ x ៣ម៉។ គេអាចដាំដើមខ្នុរការ៉ុតបានពី ១០០០ ទៅ ១ ១០០ដើមក្នុង១ហិកតា។ ដីក្នុង រណ្ដៅដែលជីកចេញឡើងមកត្រូវចែកជាពីរគំនរ ដីមុខលើ និងដីស្រទាប់ខាងក្រោម ហើយហាលដីនោះឱ្យស្ងួត ប្រមាណ ៥ថ្ងៃដើម្បីសម្លាប់មេរោគ។

-ដាក់ជីកំប៉ុសទ្រាប់បាត ពី២ទៅ៥គ.ក/រណ្ដៅ

-ដាក់ថ្នាំកណ្ដៀរ ១គ.ក/១០រណ្ដៅ

-ត្រូវទុករណ្ដៅដែលរៀបចំហើយក្នុងរយៈពេល ២ទៅ ៣ សប្ដាហ៍

**ខ)-ការជ្រើសរើសពូជ ÷**

-ត្រូវជ្រើសរើសពូជខ្នុរបំបៅ ព្រោះវាមានពូជសុទ្ធល្អ ឆាប់បានផ្លែ

-រើសយកពូជខ្នុរមានខ្លែបច្រើនសាច់ក្រាស់។

**គ)-ការដាំ÷** ជាទូទៅដើមខ្នុរអាចដាំបានគ្រប់រដូវ ចំពោះដីខ្ពង់រាបមិនជាំទឹកគួរដាំនៅរដូវភ្លៀងធ្លាក់ព្រោះ ទទួលទឹកភ្លៀងនិងសំណើមបានជាប្រចាំអាចធូរស្រាលក្នុងការស្រោចទឹក។ រីឯដីជាំទឹក មានប្រព័ន្ធទឹកគ្រប់គ្រាន់ គួរដាំក្រោយរដូវដាច់ទឹកភ្លៀង។

-កូនខ្នុរត្រូវរក្សាផ្សាំទុក១សប្ដាហ៍មុនពេលដាំ

-មុនយកទៅដាំត្រូវផ្អាកការស្រោចទឹក២ថ្ងៃលើកូនខ្នុរ ដែលផ្សាំដើម្បីកុំឱ្យបែកដី

-បកថង់ចេញកុំឱ្យបែកដី

-ដាក់កូនខ្នុរក្នុងរណ្ដៅរួចកប់ដីដោយរក្សាថង់រុំបំបៅនៅ លើដីប្រហែល១ធ្នាប់ដៃ

-លប់ដីសង្កត់ថ្នមៗរួចយកមែកឈើដោតក្បែររណ្ដៅចង ទប់ជាមួយកូនខ្នុរ។



**ឃ)- ការថែទាំ និងដាក់ជី ÷**

- កាត់ថង់រុំបំបៅចេញក្រោយដាំបាន១ខែ
- បើមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសម្លាប់សត្វល្អិត
- ដាក់ជីបំប៉នដោយប្រើជី ១៥-១៥-១៥ ឬ DAP លាយជាមួយជីធម្មជាតិអាចម៍មាន់សម្រាប់ជំនួយស្លឹក និងដើមលូតលាស់ល្អ
- កាត់សម្អាតស្មៅជុំវិញគល់ខ្នុរ (កុំប្រើថ្នាំបាញ់ស្មៅនៅក្បែរគល់ខ្នុរ)
- ប្រើថ្នាំបាញ់ស្មៅដែលនៅឆ្ងាយពីគល់ខ្នុរ
- នៅពេលខ្នុរមានក្ដិប ត្រូវបាញ់ថ្នាំការពារក្ដិបលាយជាមួយថ្នាំបំប៉នជំនួយផ្លែ
- ប្រសិនមានក្រា ត្រូវបាញ់ថ្នាំក្រា បាញ់លើផ្លែនៅពេលផ្លែធំ

**ង)- ការស្រោចទឹក ÷**

- នៅរដូវប្រាំងត្រូវស្រោចទឹក ២ដង/ សប្ដាហ៍
- រៀបប្រព័ន្ធទុយោដំណក់ទឹកដាក់តាមគល់ខ្នុរដោយ កម្រិត ៦០លីត្រ/ ម៉ោង



**ច)- ការតាក់តែងមែក ÷**

- នៅឆ្នាំទី១ត្រូវកាត់ត្រួយចុងចេញដើម្បីឱ្យបែកមែក
- កាត់មែកមិនស្រួលល្អចេញជារៀងរាល់ឆ្នាំដូចជា÷មែកចាស់មិនផ្ដល់ផ្លែ. មែកមានជម្ងឺ. មែកដុះបញ្ច្រាស់ក្អែក..



**ឆ)-របៀបប្រមូលផល ÷**

-មិនត្រូវបេះផ្លែខ្នុរទម្លាក់លើដី ពេលដើមខ្ពស់ត្រូវឡើងបេះនិងដាក់ក្នុងសង្រែកបង្ហូតចុះ

-គួរកាត់ផ្លែខ្នុរឱ្យមានជាប់ទង។

## ៩.ការសន្និដ្ឋាន

បច្ចុប្បន្ន ផ្លែខ្នុរកំពុងមានតម្រូវការទីផ្សារនាំចេញខ្ពស់ ដោយឈ្មួញចុះប្រមូលទិញដល់ចម្ការក្នុងបរិមាណ (មានប៉ុន្មានយកទាំងអស់) ព្រមទាំងមានតម្លៃសមរម្យ។ ដោយមូលហេតុនេះ កសិករក៏ដូចជាក្រុមហ៊ុនបាននាំគ្នាសម្រុកដាំដំណាំខ្នុរដែលជាប្រភេទដំណាំអចិន្ត្រៃយ៍ ងាយដាំ និងឆាប់ឱ្យផល។ ទោះជាយ៉ាងនេះក្តី គួរគិតគូអំពីតម្រូវការនិងការផ្គត់ផ្គង់នាពេលអនាគតដ៏ខ្លីខាងមុខ ព្រោះផលិតផលនេះគឺពឹងផ្អែកទាំងស្រុងលើទីផ្សារប្រទេសចិននិងវៀតណាម ក្នុងខណៈដែលប្រទេសវៀតណាមក៏កំពុងសម្រុកដាំខ្នុរប្រភេទនេះជាច្រើនដែរ។ មួយវិញទៀតប្រសិនបើការថែទាំមិនបានដឹតដល់ ធ្វើឱ្យដើមខ្នុរមានជំងឺ (ឡូងស៊ី) អាចនឹងមានការខាតបង់។

## ១០.ថ្លៃដើម និងការចំណាយលើការថែទាំដំណាំខ្នុរក្នុង១ហិកតា

(គម្លាតពីដើម១ទៅ១ដើម ៣ម៉ x ៣ម៉ ) ក្នុង១ហិកតា=១១០០ដើម ជាប្រភេទពូជថ្មីរបស់វៀតណាម ផ្លែធំ សាច់ស្រួយ ស្តង់ដារសម្រាប់នាំចេញទៅប្រទេសចិន

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) | ចំនួនសាររំលោះ | ចំណាយសរុបជាមួយការរំលោះ |
|---|---|---|---|---|---|---|
| **I-ចំណាយលើការចាប់ផ្តើមដាំដំបូង** | | | | **22,696,000** | | **15,777,905** |
| **ក.ចំណាយប្រែប្រួល** | | | | **15,016,000** | | **15,016,000** |
| ថ្លៃភ្ជួរលើកទី១ (ភ្ជួរហាលដីចោលឱ្យឆ្អិនដី) | លើក | 1 | 180,000 | 180,000 | | 180,000 |
| ថ្លៃភ្ជួរលើកទី២ ប្រៃដី និងរាស់ | លើក | 1 | 180,000 | 180,000 | | 180,000 |
| ភ្ជួរពូនរង (ដើម្បីកុំឱ្យជាំទឹក) កម្ពស់ ០.៤ម៉ ទទឹងរង ៣ម៉ ដាំកណ្តាលរង | លើក | 1 | 180,000 | 180,000 | | 180,000 |
| ឈ្នួលកាប់រណ្តៅ និងដាំ (រណ្តៅជម្រៅ០.៤ម៉ ទំហំ ០.៤ម៉ x ០.៤ម៉) | រណ្តៅ | 1100 | 4,000 | 4,400,000 | | 4,400,000 |
| ដីកំប៉ុសទ្រាប់បាត ពី២ទៅ៥គ.ក/រណ្តៅ (គិត៥គ.ក/រណ្តៅ x១១០០រណ្តៅ) ដីកំប៉ុសតម្លៃ ១២០ $/តោន | តោន | 5.5 | 492,000 | 2,706,000 | | 2,706,000 |
| ថ្នាំសម្លាប់សត្វល្អិត (ថ្នាំកណ្តៀរ ) ប្រើ១គ.ក/១០រណ្តៅ=៥០គ.ក | គ.ក | 110 | 2,000 | 220,000 | | 220,000 |
| ពូជ (១១០០ដើម x ៦៥០០៛/ដើម) (ពូជរបស់សួនកសិកម្មដំណាំខ្នុរ Lifegro IV) | ដើម | 1100 | 6,500 | 7,150,000 | | 7,150,000 |
| **ខ.ចំណាយមិនប្រែប្រួល** | | | | **7,680,000** | | **761,905** |
| ប្រព័ន្ធទឹក ទុយោដំណក់ ( ៤០០ដុល្លារ/ហ.ត រយៈពេលប្រើប្រាស់ ១៥ឆ្នាំ ) | សរុប | | | 1,600,000 | 15 | 106,667 |
| ម៉ាស៊ីនបូមទឹក កម្លាំង៨សេស + ក្បាលបូម (រយៈពេលប្រើប្រាស់ពី៥ ទៅ១០ ឆ្នាំ) | ឈុត | 1 | 3,280,000 | 3,280,000 | 7 | 468,571 |
| ដីកស្រះ (៥០០០ម៉ែត្រគីប) (ប្រើប្រាស់ ១៥ឆ្នាំ) | | | | 2,800,000 | 15 | 186,667 |

| | | | | | | |
|---|---|---|---|---|---|---|
| **II-ចំណាយលើការថែទាំឆ្នាំទី១** | | | | **4,761,600** | | **4,761,600** |
| ថ្នាំសម្លាប់សត្វល្អិតនិងថ្នាំបំប៉ន (៣ខែបាញ់ម្តង (៤ដង/ឆ្នាំ) ១ឈុត ១ឈុតតម្លៃ ១០០០០០៛/ម្តង | ដង | 4 | 100,000 | 400,000 | | 400,000 |
| ឈ្នួលបាញ់ថ្នាំសត្វល្អិតនិងថ្នាំបំប៉ន | ដង | 4 | 100,000 | 400,000 | | 400,000 |
| ជី DAP ដាក់ម្តង២៥គ.ក/ហ.ត ១ឆ្នាំដាក់៤ដង=១០០គ.ក=២ការុង | ការុង | 2 | 120,000 | 240,000 | | 240,000 |
| ជីអាចម៍មាន់ធម្មជាតិ ២គ.ក/គុម្ព ដាក់២ដង/ឆ្នាំ x១១០០គុម្ព= ៤៤០០គ.ក ១ការុង=២៤គ.ក តម្លៃ ២០០០៛/ការុង | ការុង | 183 | 2,000 | 366,000 | | 366,000 |
| ឈ្នួលកាត់ស្មៅជុំវិញគល់ ៦ដង/ឆ្នាំ, ៤ថ្ងៃ/ម្តង, ៤០០០០៛/ថ្ងៃ | ដង | 24 | 40,000 | 960,000 | | 960,000 |
| ថ្នាំបាញ់ស្មៅ (៦ដង/ឆ្នាំ) | ដង | 6 | 79,000 | 474,000 | | 474,000 |
| ឈ្នួលបាញ់ថ្នាំស្មៅ | ដង | 6 | 100,000 | 600,000 | | 600,000 |
| ម៉ាស៊ូតបូមទឹក ស្រោចរយៈពេល៦ខែ នៅរដូវប្រាំង ១ខែស្រោច៨ដង (១សប្តាហ៍ស្រោច២ដង=៤៨ដង ម្តង ៦លីត្រ=២៨៨លីត្រ | លីត្រ | 288 | 3,200 | 921,600 | | 921,600 |
| ថ្លៃតាក់តែងមែក (កាត់ត្រួយចុងចេញ) ២នាក់ x ៥ថ្ងៃ | ថ្ងៃ/នាក់ | 10 | 40,000 | 400,000 | | 400,000 |
| **III-ចំណាយលើការថែទាំឆ្នាំទី២** | | | | **6,361,600** | | **6,361,600** |
| ថ្នាំសម្លាប់សត្វល្អិតនិងថ្នាំបំប៉ន (៣ខែបាញ់ម្តង (៤ដង/ឆ្នាំ) | ដង | 4 | 100,000 | 400,000 | | 400,000 |
| ឈ្នួលបាញ់ថ្នាំសត្វល្អិតនិងថ្នាំបំប៉ន | ដង | 4 | 100,000 | 400,000 | | 400,000 |
| ជី DAP ដាក់ម្តង២៥គ.ក/ហ.ត ១ឆ្នាំដាក់៤ដង=១០០គ.ក=២ការុង | ការុង | 2 | 120,000 | 240,000 | | 240,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ជីអាចម៍មាន់ធម្មជាតិ ២គ.ក/គុម្ព ដាក់២ដង/ឆ្នាំ x១១០០គុម្ព= ៤៤០០គ.ក<br>១ការុង= ២៤គ.ក តម្លៃ ២០០០៛/ការុង | ការុង | 183 | 2,000 | 366,000 | | 366,000 |
| ឈ្នួលកាត់ស្មៅជុំវិញគល់ ៦ដង/ឆ្នាំ, ៤ថ្ងៃ/ម្តង, ៤០០០០៛/ថ្ងៃ | ដង | 24 | 40,000 | 960,000 | | 960,000 |
| ថ្នាំបាញ់ស្មៅ (៦ដង/ឆ្នាំ) | ដង | 6 | 79,000 | 474,000 | | 474,000 |
| ឈ្នួលបាញ់ថ្នាំស្មៅ | ដង | 6 | 100,000 | 600,000 | | 600,000 |
| ម៉ាស៊ូតបូមទឹក ស្រោចរយៈពេល៦ខែ នៅរដូវប្រាំង<br>១ខែស្រោច៨ដង (១សប្តាហ៍ស្រោច២ដង= ៤៨ដង ម្តង ៦លីត្រ= ២៨៨លីត្រ | លីត្រ | 288 | 3,200 | 921,600 | | 921,600 |
| ថ្លៃតាក់តែងមែក (កាត់មែកមិនស្ងួវល្អចេញ) ២នាក់ x ៥ថ្ងៃ | ថ្ងៃ/នាក់ | 10 | 40,000 | 400,000 | | 400,000 |
| បាញ់ថ្នាំការពារក្តិបលាយជាមួយថ្នាំបំប៉នជំនួយផ្លែ (ថ្លៃថ្នាំ + ឈ្នួលបាញ់) | លើក | 4 | 200,000 | 800,000 | | 800,000 |
| ថ្នាំក្រា បាញ់លើផ្លែ នៅពេលផ្លែធំ ប្រសិនមានក្រា | លើក | 4 | 200,000 | 800,000 | | 800,000 |
| **ចំណាយសរុបពីការចាប់ផ្តើមដាំ និងការថែទាំរហូតដល់ឆ្នាំទី២** | | | | **33,819,200** | | **26,901,105** |
| **ការវិភាគសេដ្ឋកិច្ចសម្រាប់ឆ្នាំទី២** | | | | | | |
| **ចំណាយសរុប**<br>(ចំណាយប្រែប្រួល+ចំណាយរំលោះលើកទី១+ចំណាយលើការថែទាំឆ្នាំទី១ +ឆ្នាំទី២) | | | | | | **26,901,105** |
| **ចំណូល**សម្រាប់ការប្រមូលផលវគ្គទី១នៅខែទី១៨ ) ពី១២ទៅ១៣ខែចេញផ្កាក្តិប<br>ពីខែទី១៨ទៅ១៩ បេះ ក្នុង១ដើមទុកខ្នុរ១ផ្លែ ទម្ងន់ពី៩ទៅ១៥គ.ក/ផ្លែ<br>គិតជាមធ្យម ១០គ.ក/ផ្លែ និងទទួលផល៤០% លើដើមខ្នុរសរុប<br>ដូចនេះ ក្នុង១១០០ដើម ឱ្យផល ៤៤០ដើម x ១០គ.ក/ដើម = ៤៤០០គ.ក | គ.ក | 4,400 | 2,000 | **8,800,000** | | **8,800,000** |
| **ចំណូល** សម្រាប់ការប្រមូលផលនៅវគ្គទី២ខែទី២២ទៅខែទី២៤ )<br>ក្នុង១ដើមទុកខ្នុរ១ផ្លែ ទម្ងន់ពី៩ទៅ១៥គ.ក/ផ្លែ<br>គិតជាមធ្យម ១០គ.ក/ផ្លែ និងទទួលផល៤០% លើដើមខ្នុរសរុប ខ្នុរមូលនិងត្រូវខ្នាត | គ.ក | 4,400 | 2,000 | **8,800,000** | | **8,800,000** |

| | | | | | | |
|---|---|---|---|---|---|---|
| ដូចនេះ ក្នុង១១០០ដើម ឱ្យផល ៤៤០ដើម x ១០គ.ក/ដើម = ៤៤០០គ.ក | | | | | | |
| **លទ្ធផលក្នុងឆ្នាំទី២** | | | | | | **(9,301,105)** |
| **III-ចំណាយលើការថែទាំឆ្នាំទី៣** | | | | **4,327,600** | | **4,327,600** |
| ថ្នាំសម្លាប់សត្វល្អិតនិងថ្នាំបំប៉ន (៣ខែបាញ់ម្តង (៤ដង/ឆ្នាំ) ១ឈុត ១ឈុតតម្លៃ ១០០០០០៛/ម្តង | ដង | 4 | 100,000 | 400,000 | | 400,000 |
| ឈ្នួលបាញ់ថ្នាំសត្វល្អិតនិងថ្នាំបំប៉ន | ដង | 4 | 100,000 | 400,000 | | 400,000 |
| ជី DAP ដាក់ម្តង២៥គ.ក/ហ.ត ១ឆ្នាំដាក់៤ដង=១០០គ.ក=២ការុង | ការុង | 2 | 120,000 | 240,000 | | 240,000 |
| ជីអាចម៍មាន់ធម្មជាតិ ២គ.ក/គុម្ព ដាក់២ដង/ឆ្នាំ x១១០០គុម្ព=៤៤០០គ.ក ១ការុង=២៤គ.ក តម្លៃ ២០០០៛/ការុង | ការុង | 183 | 2,000 | 366,000 | | 366,000 |
| ម៉ាស៊ូតបូមទឹក ស្រោចរយៈពេល៦ខែ នៅរដូវប្រាំង ១ខែស្រោច៨ដង (១សប្តាហ៍ស្រោច២ដង=៤៨ដង ម្តង ៦លីត្រ=២៨៨លីត្រ | លីត្រ | 288 | 3,200 | 921,600 | | 921,600 |
| ថ្លៃតាក់តែងមែក (កាត់មែកមិនស្រួលចេញ) ២នាក់ x ៥ថ្ងៃ | ថ្ងៃ/នាក់ | 10 | 40,000 | 400,000 | | 400,000 |
| បាញ់ថ្នាំការពារក្តីបលាយជាមួយថ្នាំបំប៉នជំនួយផ្លែ (ថ្លៃថ្នាំ + ឈ្នួលបាញ់) | លើក | 4 | 200,000 | 800,000 | | 800,000 |
| ថ្នាំក្រា បាញ់លើផ្លែ នៅពេលផ្លែធំ ប្រសិនមានក្រា | លើក | 4 | 200,000 | 800,000 | | 800,000 |
| **ការវិភាគសេដ្ឋកិច្ចសម្រាប់ឆ្នាំទី៣** | | | | | | |
| • ចំណាយលើការថែទាំឆ្នាំទី៣ | | | | | | 4,327,600 |

| | | | | | | |
|---|---|---|---|---|---|---|
| • ចំណាយលើការរំលស់ប្រចាំឆ្នាំ | | | | | | 761,905 |
| • លទ្ធផលខាត/ចំណេញនៅក្នុងឆ្នាំទី២ | | | | | | (9,301,105) |
| **ចំណូលពីការលក់ខ្នុរក្នុងឆ្នាំទី៣**<br>ចាប់ពីឆ្នាំទី៣ ការប្រមូលផលគឺបន្តបន្ទាប់គ្នារយៈពេលពេញ១ឆ្នាំ ជាសរុបគឺ÷<br>ក្នុង១ដើមទុកពី៣ទៅ៤ផ្លែ គិតជាមធ្យម ៣ផ្លែ/ដើម ទម្ងន់គិតជាមធ្យម ១០គ.ក/ផ្លែ ស្មើនឹង ៣០គ.ក/ដើមនិងផ្តល់ផល៨០% លើចំនួនដើមសរុប= ៨៨០ដើម ដែលឱ្យផលល្អ<br>ស្មើនឹង ៣០គ.ក/ដើម x ៨៨០ដើម = ២៦.៤០០គ.ក | គ.ក | 26,400 | 2,000 | 52,800,000 | | 52,800,000 |
| **លទ្ធផលក្នុងឆ្នាំទី៣** | | | | | | **38,409,390** |

**សម្គាល់÷**

-ដំណាំខ្នុរការ៉ុតគឺទទួលបានប្រាក់ចំណេញចាប់ពីឆ្នាំទី៣ឡើងទៅ

-លទ្ធផលខាងលើគឺគិតលើទិន្នផល និងតម្លៃដែលទាបបំផុត (ទិន្នផលពី៣ ទៅ៤ផ្លែ/ដើម តែគិតជាមធ្យមតែ៣ផ្លែ/ដើម រីឯទម្ងន់គឺពី១០ ទៅ១៥គ.ក/ផ្លែ ប៉ុន្តែគិតជាមធ្យមតែ១០គ.ក/ផ្លែ និងតម្លៃបច្ចុប្បន្នគឺពី ២០០០៛ ទៅ ២៦០០០៛/គ.ក ប៉ុន្តលើកយកតែតម្លៃ ២០០០៛/គ.កតែប៉ុណ្ណោះ)។

-ចាប់ពីឆ្នាំទី៤ ក្នុង១ដើមអាចមានពី ៥-៧ ផ្លែ គិតជាមធ្យម ៦ផ្លែ/ដើម ដែលជាប្រភេទផ្លែល្អ ទម្ងន់ពី ១០ ទៅ ២០គ.ក/ផ្លែ និងអាចឱ្យផលរហូត ៩៥% នៃចំនួនដើមដែលដាំ ហើយប្រាក់ចំណេញក៏មានការកើនឡើងដែរ។

-ចំណាយលើការថែទាំក្នុងឆ្នាំទី៤ គឺមានការកើនឡើងលើការបាញ់ថ្នាំសត្វល្អិត និងថ្នាំក្រា។